# និយ័តករគណនេយ្យនិងសវនកម្ម

## ព្រឹត្តិបត្រព័ត៌មានប្រចាំខែកុម្ភៈ ឆ្នាំ២០២៥

លេខ:០០២

សេចក្ដីសង្ខេបព័ត៌មាន និងព្រឹត្តិការណ៍សំខាន់ៗប្រចាំខែកុម្ភៈ របស់និយ័តករគណនេយ្យ និងសវនកម្ម នៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ រួមមានដូចខាងក្រោម៖

## កិច្ចប្រជុំគណៈកម្មាធិការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ



១.កាលពីអង្គារ ៧ កើត ខែមាឃ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី៤ ខែកុម្ភៈ គ.ស.២០២៥ **ឯកឧត្តម ប៊ូ ថារិន អគ្គនាយក** នៃនិយ័តករគណនេយ្យនិងសវនកម្ម អមដោយមន្ត្រីបច្ចេកទេសបានចូលរួមកិច្ចប្រជុំគណៈកម្មាធិការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដើម្បីពិនិត្យនិងពិភាក្សាលើរបាយការណ៍ប្រចាំឆ្នាំ២០២៤ នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី៤តាមប្រព័ន្ធអនឡាញ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងការងារហិរញ្ញវត្ថុសាធារណៈ**។

## កិច្ចប្រជុំក្រុមប្រឹក្សា អ.ស.ហ. អាណត្តិទី១ លើកទី២២



២.កាលពីថ្ងៃពុធ ១៥កើត ខែមាឃ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី១២ ខែកុម្ភៈ គ.ស.២០២៥ **ឯកឧត្តម ប៊ូ ថារិន អគ្គនាយក** នៃនិយ័តករគណនេយ្យនិងសវនកម្ម

## ព័ត៌មានថ្មីៗ

កិច្ចប្រជុំ សូមអាននៅទំព័រ..........១
កិច្ចប្រជុំ សូមអាននៅទំព័រ..........១
សិក្ខាសាលាផ្សព្វផ្សាយ សូមអាននៅទំព័រ ..........២
កិច្ចប្រជុំ សូមអាននៅទំព័រ..........២
វេទិកាគណនេយ្យករ សូមអាននៅទំព័រ..........៣
កិច្ចប្រជុំ សូមអាននៅទំព័រ..........៣
ពិធីបញ្ចប់ការសាងសង់ សូមអាននៅទំព័រ..........៤
កិច្ចប្រជុំ សូមអាននៅទំព័រ..........៤
កិច្ចប្រជុំ សូមអាននៅទំព័រ..........៥
វេទិកាសាធារណៈ សូមអាននៅទំព័រ..........៦
កិច្ចប្រជុំ សូមអាននៅទំព័រ..........៦
វគ្គបណ្ដុះបណ្ដាលស្ដីពី សូមអាននៅទំព័..........៦
កិច្ចប្រជុំ សូមអាននៅទំព័..........៧
វគ្គបណ្ដុះបណ្ដាលស្ដីពី សូមអាននៅទំព័រ..........៧
កម្មវិធីចែកវិញ្ញាបនបត្រ សូមអាននៅទំព័រ..........៨
កិច្ចប្រជុំ សូមអាននៅទំព័រ..........៨
កិច្ចប្រជុំ សូមអាននៅទំព័រ..........៩
កិច្ចប្រជុំ សូមអាននៅទំព័រ..........៩
កិច្ចប្រជុំ សូមអាននៅទំព័រ..........១០
កិច្ចប្រជុំ សូមអាននៅទំព័រ..........១១
កិច្ចប្រជុំ សូមអាននៅទំព័រ..........១១
កិច្ចប្រជុំ សូមអាននៅទំព័រ..........១១
ពិធីចុះហត្ថលេខា សូមអាននៅទំព័រ..........១២
វគ្គបណ្ដុះបណ្ដាលស្ដីពី សូមអាននៅទំព័រ..........១២
កិច្ចប្រជុំ សូមអាននៅទំព័រ..........១៣
សិក្ខាសាលាផ្សព្វផ្សាយស្ដីពី សូមអាននៅទំព័រ..........១៣
កិច្ចប្រជុំ សូមអាននៅទំព័រ..........១៣
កិច្ចប្រជុំ សូមអាននៅទំព័រ..........១៤
ចូលរួមសន្និបាត សូមអាននៅទំព័រ..........១៥
សិក្ខាសាលាផ្សព្វផ្សាយ សូមអាននៅទំព័រ..........១៥
សិក្ខាសាលាផ្សព្វផ្សាយ សូមអាននៅទំព័រ..........១៦
សិក្ខាសាលាផ្សព្វផ្សាយ សូមអាននៅទំព័រ..........១៧

© រក្សាសិទ្ធិដោយ និយ័តករគណនេយ្យនិងសវនកម្ម

និងជាសមាជិកក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ បានអញ្ជើញចូលរួមកិច្ចប្រជុំក្រុមប្រឹក្សា **អ.ស.ហ.** អាណត្តិទី១ លើកទី២២ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សា** អ.ស.ហ ដែលបានប្រព្រឹត្តទៅនៅសាលប្រជុំនៃទីស្តីការ **អ.ស.ហ.**។

## សិក្ខាសាលាផ្សព្វផ្សាយប្រកាសស្ដីពីសេវាសាធារណៈរបស់និយ័តករគណនេយ្យនិងសវនកម្ម




៣.កាលពីថ្ងៃច័ន្ទ ៦កើត ខែមាឃ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី៣ ខែកុម្ភៈ គ.ស.២០២៥ និយ័តករគណនេយ្យនិងសវនកម្ម បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយប្រកាសស្តីពីសេវាសាធារណៈរបស់និយ័តករគណនេយ្យនិងសវនកម្ម តាមរយៈប្រព័ន្ធអនឡាញ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ម៉ូ ថារិន អគ្គនាយក** នៃនិយ័តករគណនេយ្យនិងសវនកម្ម ដោយមានការអញ្ជើញចូលរួមពីសិក្ខាកាមមកពីស្ថាប័នរដ្ឋ និងឯកជនសរុប ២១២នាក់។

## កិច្ចប្រជុំលើកទី៥ របស់អនុគណៈកម្មាធិការអភិវឌ្ឍកម្មវិធីសិក្សា នៃគណៈកម្មាធិការគ្រប់គ្រងកម្មវិធីសិក្សាគណនេយ្យករជំនាញកម្ពុជា



៤.កាលពីថ្ងៃចន្ទ ៦កើត ខែមាឃ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី៣ ខែកុម្ភៈ គ.ស.២០២៥ **លោក ហុង ពិសិដ្ឋ** ប្រធានអនុ-គណៈកម្មាធិការអភិវឌ្ឍកម្មវិធីសិក្សា បានដឹកនាំកិច្ចប្រជុំលើកទី៥របស់អនុគណៈកម្មាធិការអភិវឌ្ឍកម្មវិធីសិក្សានៃគណៈកម្មាធិការគ្រប់គ្រង

កម្មវិធីសិក្សាគណនេយ្យករជំនាញកម្ពុជា ដោយមានការអញ្ជើញចូលរួមពី លោក លោកស្រី ដែលជាសមាជិក និងក្រុមលេខាធិការដ្ឋាន តាមប្រព័ន្ធអនឡាញ ដើម្បីពិនិត្យលើវឌ្ឍនភាពការងារកម្មវិធីសិក្សាក្នុងឆ្នាំ២០២៤ ព្រមទាំងពិនិត្យ និងពិភាក្សាសៀវភៅសិក្សា សម្រាប់ការដាក់ឱ្យដំណើរការនៃការចុះឈ្មោះចូលរៀនជូនដល់សាធារណជន សិស្ស និស្សិត នៅឆមាសទី១ ឆ្នាំ២០២៥ខាងមុខនេះ។

## វេទិកាគណនេយ្យករពិភពលោកឆ្នាំ២០២៥




៥.កាលពីថ្ងៃទី៣១ ខែមករា ដល់ថ្ងៃទី២ ខែកុម្ភៈ គ.ស.២០២៥ ដោយទទួលបានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម ម៉ុ ថារិន អគ្គនាយក** នៃនិយ័តករគណនេយ្យនិងសវនកម្ម លោក ណុប សម្បត្តិ អនុប្រធាននាយកដ្ឋានគ្រប់គ្រងវិជ្ជាជីវៈ អមដោយ លោក ស៊ុន ស៊ឹម ប្រធានការិយាល័យអាជ្ញាបណ្ណ លោក ជីវ ហ៊ា ប្រធានការិយាល័យគ្រប់គ្រងព័ត៌មានវិទ្យា និងកញ្ញា សុខ ណារី ប្រធានការិយាល័យផ្សព្វផ្សាយនិងបណ្តុះបណ្តាល បានចូលរួមវេទិកាគណនេយ្យករពិភពលោកឆ្នាំ២០២៥ នៅទីក្រុងញ៉ូដេលី ដែលរៀបចំដោយ វិទ្យាស្ថានគណនេយ្យករនៃប្រទេសឥណ្ឌា (ICAI) នៅមជ្ឈមណ្ឌល Yashobhoomi Convention Center ប្រទេសឥណ្ឌា ដែលបានប្រព្រឹត្តិទៅរយៈពេល៣ថ្ងៃ ។ វេទិកានេះរៀបចំក្នុងគោលបំណងស្វែងយល់ពីសក្តានុពលផ្លាស់ប្តូររបស់បញ្ញាសិប្បនិម្មិត ដើម្បីដោះស្រាយបញ្ហាប្រឈមបរិស្ថានជាសកល ដូចជាការប្រែប្រួលអាកាសធាតុ ការបំពុលនិងកង្វះធនធានព្រមទាំងពន្លឿនការអភិវឌ្ឍន៍និងការទទួលយកដំណោះស្រាយបញ្ញាសិប្បនិម្មិតដែលរួមចំណែក ដល់ការអភិវឌ្ឍន៍ប្រកបដោយចីរភាព។

## កិច្ចប្រជុំជាមួយ និយ័តករមូលបត្រកម្ពុជា



៦.កាលពីថ្ងៃពុធ ៨កើត ខែមាឃ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី៥ ខែកុម្ភៈ គ.ស.២០២៥ **លោកស្រី នាន បូនី** អគ្គនាយករងតំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ម៉ុ ថារិន អគ្គនាយក** នៃនិយ័តករគណនេយ្យនិងសវនកម្ម អមដោយ មន្ត្រីជំនាញបានចូលរួមកិច្ចប្រជុំជាមួយនិយ័តករមូលបត្រកម្ពុជា ក្នុងគោលបំណងពិគ្រោះ និងពិភាក្សាលើកម្រិតបច្ចេកទេសស្តីពីសេចក្តីព្រាងប្រកាស "ការអនុវត្តស្តង់ដាការលាតត្រដាងព័ត៌មានចីរភាព IFRS S1 និងIFRS S2 " នៅបន្ទប់ប្រជុំអគារ៣៤៥។

## ពិធីបញ្ចប់ការសាងសងជាន់កំពូលនៃអគារមជ្ឈមណ្ឌលហិរញ្ញវត្ថុអន្តរជាតិ



៧.កាលពីថ្ងៃព្រហស្បតិ៍ ៩កើត ខែមាឃ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី៦ ខែកុម្ភៈ គ.ស.២០២៥ **ឯកឧត្តម ម៉ី ថារិន អគ្គនាយក** នៃនិយ័តករគណនេយ្យនិងសវនកម្ម បានចូលរួមពិធីបញ្ចប់ការសាងសងជាន់កំពូលនៃអគារមជ្ឈមណ្ឌលហិរញ្ញវត្ថុអន្តរជាតិ និងចុះត្រួតពិនិត្យលើវឌ្ឍនភាពនៃការអភិវឌ្ឍគម្រោង Bay of Lights របស់ក្រុមហ៊ុន Canopy Sands Development ( CSD ) នៅខេត្តព្រះសីហនុ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម រស់ សីលវ៉ា រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមការងារមជ្ឈមណ្ឌលហិរញ្ញវត្ថុ។**

## កិច្ចប្រជុំស្តីពីការត្រួតពិនិត្យឡើងវិញរួមគ្នាលើការអនុវត្តគម្រោងវិនិយោគសាធារណៈ ហិរញ្ញប្បទានពីដៃគូអភិវឌ្ឍឆ្នាំ២០២៤




៨.កាលពីថ្ងៃសុក្រ ១០កើត ខែមាឃ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី៧ ខែកុម្ភៈ គ.ស.២០២៥ ដោយមានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ម៉ី ថារិន អគ្គនាយក** នៃនិយ័តករគណនេយ្យនិងសវនកម្ម លោក ទឹម សត្យា អនុប្រធាននាយកដ្ឋានទទួលបន្ទុករួមនៃនាយកដ្ឋានកិច្ចការទូទៅ និង លោកស្រី ហា សុគន្ធា ប្រធានការិយាល័យគណនេយ្យនិងសវនកម្ម បានចូលរួមកិច្ចប្រជុំស្តីពីការត្រួតពិនិត្យឡើងវិញរួមគ្នាលើការអនុវត្តគម្រោងវិនិយោគសាធារណៈហិរញ្ញប្បទានពីដៃគូអភិវឌ្ឍឆ្នាំ២០២៤ ( 2024 Joint Country Portfolio Performance Review - JCPPR" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ប៉ែន ធីរុទ្ធ រដ្ឋលេខាធិការ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** កិច្ចប្រជុំនេះ មានការអញ្ជើញចូលរួមពីសំណាក់តំណាងដៃគូអភិវឌ្ឍពាក់ព័ន្ធ ឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលជានាយកគម្រោង ប្រធានគ្រប់គ្រងគម្រោង និងមន្ត្រីពាក់ព័ន្ធរបស់គម្រោងហិរញ្ញប្បទានពីដៃគូអភិវឌ្ឍ តាមប្រព័ន្ធអនឡាញផងដែរ។ កិច្ចប្រជុំខាងលើត្រូវបានរៀបចំឡើងក្នុងគោលបំណងពិនិត្យនិងពិភាក្សាលើការរៀបចំ JCPPR ឆ្នាំ២០២៤ ពិសេសលើវិធីសាស្ត្រ និងក្របខ័ណ្ឌពេលវេលាក្នុងការ

ប្រមែប្រមូលទិន្នន័យសម្រាប់ជាធាតុចូលក្នុងការរៀបចំរបាយការណ៍ត្រួតពិនិត្យឡើងវិញរួមគ្នាលើការអនុវត្តគម្រោងវិនិយោគសាធារណៈហិរញ្ញប្បទានពីដៃគូអភិវឌ្ឍឆ្នាំ២០២៤ ព្រមទាំងផែនការសកម្មភាពរួមសម្រាប់ឆ្នាំ២០២៥ សំដៅធ្វើឱ្យការអនុវត្តគម្រោងកាន់តែមានភាពប្រសើរឡើង។

## កិច្ចប្រជុំអន្តរក្រសួងដើម្បីពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យស្តីពីការពិន័យអន្តរការណ៍ចំពោះបទល្មើសនឹងច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម



៩.កាលពីថ្ងៃសុក្រ ១០កើត ខែមាឃ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី៧ ខែកុម្ភៈ គ.ស.២០២៥ នៅអគារភាតរភាព សាល៧-៨ ជាន់ទី៧ នៃទីស្តីការគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាព **ឯកឧត្តមបណ្ឌិតសភាចារ្យ ហ៊ីង ថូរ៉ាក់ស៊ី រដ្ឋមន្ត្រីស្តីទីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី** បានដឹកនាំកិច្ចប្រជុំអន្តរក្រសួង ដើម្បីពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យស្តីពីការពិន័យអន្តរការណ៍ចំពោះបទល្មើសនឹងច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម។ កិច្ចប្រជុំមានការអញ្ជើញចូលរួមពី **ឯកឧត្តម ងី តាយី រដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុទទួលបន្ទុកនិយ័តករគណនេយ្យនិងសវនកម្ម អមដោយ **ឯកឧត្តម ម៉ូ ថារិន អគ្គនាយក** នៃ **ន.គ.ស.** ព្រមទាំងថ្នាក់ដឹកនាំនិងមន្ត្រីជំនាញ **ន.គ.ស.** តំណាងក្រុមប្រឹក្សាអ្នកច្បាប់, តំណាងក្រុមប្រឹក្សាសេដ្ឋកិច្ច, សង្គមកិច្ច និងវប្បធម៌ និងតំណាងក្រសួងស្ថាប័ន និងអង្គភាពពាក់ព័ន្ធចំនួន២៨ សរុបប្រមាណ៩០នាក់ ។

## វេទិកាសាធារណៈស្តីពី "ការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ច និងច្បាប់ថវិកាឆ្នាំ២០២៥"



១០.កាលពីថ្ងៃចន្ទ ១៣កើត ខែមាឃ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី១០ ខែកុម្ភៈ គ.ស.២០២៥ **ឯកឧត្តម ម៉ូ ថារិន អគ្គនាយក** នៃនិយ័តករគណនេយ្យនិងសវនកម្ម អមដោយ មន្ត្រីជំនាញបានអញ្ជើញចូលរួមវេទិកាសាធារណៈស្តីពី "ការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ច និងច្បាប់ថវិកាឆ្នាំ២០២៥" ដែលប្រព្រឹត្តទៅនៅសណ្ឋាគារ សូហ្វីតែល ភ្នំពេញភូគីត្រា ក្រោមអធិបតីភាព **ឯកឧត្តមបណ្ឌិត ផាន់ ផល្លា** និង **ឯកឧត្តម ចាន់ សុធី រដ្ឋលេខាធិការ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**។

## កិច្ចប្រជុំអន្តរក្រសួងដើម្បីពិនិត្យពិភាក្សាលើសេចក្តីព្រាងរបាយការណ៍ស្តីពីវឌ្ឍនភាពការងារ ប្រចាំឆ្នាំឆមាសទី២ ឆ្នាំ២០២៤



១១.កាលពីថ្ងៃចន្ទ១៣កើត ខែមាឃ ឆ្នាំរោង ឆស័កព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី១០ ខែកុម្ភៈគ.ស.២០២៥ ដោយមានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម ម៉ូ ថារិន អគ្គនាយក** នៃនិយ័តករគណនេយ្យ និងសវនកម្ម លោក លី កុសល អនុប្រធាននាយកដ្ឋានទទួលបន្ទុករួមនៃនាយដ្ឋានកិច្ចការយុត្តនិងអនុលោមភាព ព្រមទាំងមន្ត្រីជំនាញ បានចូលរួមកិច្ចប្រជុំអន្តរក្រសួងដើម្បីពិនិត្យពិក្សាលើសេចក្តីព្រាងរបាយការណ៍ស្តីពីវឌ្ឍនភាពការងារប្រចាំឆ្នាំឆមាសទី២ ឆ្នាំ២០២៤ នៃយន្តការវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន ក្រោមអធិបតីភាព **ឯកឧត្តម នុត អ៊ុនវ័ណ្ណារ៉ា អគ្គលេខាធិការរងគណៈកម្មាធិការវិនិយោគកម្ពុជា**។

## វគ្គបណ្តុះបណ្តាលស្តីពីថ្នាលរៀបចំរបាយការណ៍ហិរញ្ញវត្ថុឌីជីថល សម្រាប់សហគ្រាសធុនតូចនិងមធ្យមនិងអង្គភាពមិនស្វែងរកប្រាក់ចំណេញ




១២.កាលពីថ្ងៃអង្គារ ១៤កើត ខែមាឃ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី១១ ខែកុម្ភៈ គ.ស ២០២៥ និយ័តករគណនេយ្យនិងសវនកម្មនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពីថ្នាលរៀបចំរបាយការណ៍ហិរញ្ញវត្ថុឌីជីថលសម្រាប់សហគ្រាសធុនតូចនិងមធ្យមនិងអង្គភាពមិនស្វែងរកប្រាក់ចំណេញវគ្គទី៨ដែលប្រព្រឹត្តទៅក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ម៉ូ ថារិន អគ្គនាយក** នៃនិយ័តករគណនេយ្យនិងសវនកម្ម អមដោយថ្នាក់ដឹកនាំ និងមន្ត្រីជំនាញនៃនិយ័តករគណនេយ្យនិងសវនកម្ម។ **ឯកឧត្តមអគ្គនាយក** បានរំលេចនូវអត្ថប្រយោជន៍មួយចំនួននៃថ្នាលរៀបចំរបាយការណ៍ហិរញ្ញវត្ថុឌីជីថលសម្រាប់សហគ្រាសធុនតូចនិងមធ្យមនិងអង្គភាពមិនស្វែងរកប្រាក់ចំណេញរួមមាន ១.ជួយសម្រួលដំណើការរៀបចំនិងកាត់បន្ថយចំណាយក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ និងកំណត់សម្គាល់

ដោយផ្អែកតាមទម្រង់រួមបែបឱជីថលនិងទិន្នន័យដែលស្របតាមស្តង់ដាគណនេយ្យ ២.ជួយកាត់បន្ថយកំហុសឆ្គងនិងបង្កើនកម្រិតអនុលោមភាពក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុតាមរយៈគោលការណ៍ផ្ទៀងផ្ទាត់អនុលោមភាពដោយស្វ័យប្រវត្តិក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុបែបឱជីថល ៣.បង្កើនគុណភាពនៃរបាយការណ៍ហិរញ្ញវត្ថុដែលអនុលោមតាមស្តង់ដាដោយផ្អែកតាមវិធីសាស្ត្រគណនេយ្យរបស់ស្តង់ដាគណនេយ្យអន្តរជាតិនិង ៤.បង្កើនគុណភាពនៃការសម្រេចចិត្តនិងការវិនិយោគ ដោយផ្អែកតាមការវិភាគអនុបាតហិរញ្ញវត្ថុ។

## កិច្ចប្រជុំជាមួយជំនាញការរបស់សហភាពអឺរ៉ុប




១៣.កាលពីថ្ងៃអង្គារ ១៤កើត ខែមាឃ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី១១ ខែកុម្ភៈ គ.ស.២០២៥ ដោយមានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម ចូ ថារិន អគ្គនាយក** នៃនិយ័តករគណនេយ្យនិងសវនកម្ម លោកស្រី ពេជ្រ ម៉ានីឡា អនុប្រធាននាយកដ្ឋានបច្ចេកទេស អមដោយមន្ត្រីជំនាញនៃនាយកដ្ឋានបច្ចេកទេស បានចូលរួមកិច្ចប្រជុំជាមួយជំនាញការរបស់សហភាពអឺរ៉ុប ដើម្បីពិភាក្សាអំពីផែនការលម្អិត ក្រោមជំនួយបច្ចេកទេសរបស់សហភាពអឺរ៉ុប ជូនដល់និយ័តករគណនេយ្យនិងសវនកម្ម សម្រាប់គាំទ្រការអនុវត្តសកម្មភាពកែទម្រង់គន្លឹះក្រោមក្របខណ្ឌកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៤។

## វគ្គបណ្តុះបណ្តាល"មូលដ្ឋានគ្រឹះគណនេយ្យមុននឹងសិក្សាស្តង់ដាគណនេយ្យ"



១៤.កាលពីថ្ងៃពុធ ១៥កើត ខែមាឃ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី១២ ខែកុម្ភៈ គ.ស.២០២៥ និយ័តករគណនេយ្យនិងសវនកម្មនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពី "មូលដ្ឋានគ្រឹះគណនេយ្យមុននឹងសិក្សាស្តង់ដាគណនេយ្យ" មានរយៈពេល៣ថ្ងៃ នៅអគារ ៣៨៥។ វគ្គបណ្តុះបណ្តាលវគ្គទី១ សម្រាប់ឆ្នាំ២០២៥ នេះប្រព្រឹត្តទៅក្រោមអធិបតីភាព លោក លី កុសល អនុប្រធានទទួលបន្ទុករួម នៃនាយកដ្ឋានកិច្ចការគតិយុត្តនិងអនុលោមភាពតំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ចូ ថារិន អគ្គនាយក** នៃនិយ័តករគណនេយ្យនិងសវនកម្ម អមដោយថ្នាក់ដឹកនាំ និងមន្ត្រីនៃនិយ័តករគណនេយ្យនិងសវនកម្ម។ វគ្គបណ្តុះបណ្តាលនេះត្រូវបានរៀបចំឡើងនៅក្នុងគោលដៅដើម្បីបញ្ជ្រាបការយល់ដឹងអំពីមូលដ្ឋានក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុដោយផ្តោតទៅលើផ្នែកសំខាន់ៗជាមូលដ្ឋាន

មុននឹងឈានទៅសិក្សាវគ្គស៊ីជម្រៅ គឺវគ្គស្តង់ដារបាយការណ៍ទាក់ទងនិងហិរញ្ញវត្ថុអន្តរជាតិកម្ពុជាសម្រាប់សហគ្រាសធុនតូច និងមធ្យម (CIFRS For SMEs) និងស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា (CIFRS)។

## កម្មវិធីចែកវិញ្ញាបនបត្រជូនសិក្ខាកាមដែលបានចូលរួមវគ្គបណ្តុះបណ្តាលស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់សហគ្រាសធុនតូច និងមធ្យម




១៥.កាលពីថ្ងៃសុក្រ ២រោច ខែមាឃ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី១៤ ខែកុម្ភៈ គ.ស.២០២៥ និយ័តករគណនេយ្យនិងសវនកម្ម នៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ បានរៀបចំកម្មវិធីចែកវិញ្ញាបនបត្រជូនសិក្ខាកាមដែលបានចូលរួមវគ្គបណ្តុះបណ្តាលស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់សហគ្រាសធុនតូច និងមធ្យមដែលបានចូលរួមវគ្គទី៧និងទី៨ កាលពីឆ្នាំ២០២៤កន្លងទៅ។ កម្មវិធីនេះប្រព្រឹត្តទៅក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ម៉ូ ថារិន អគ្គនាយក** នៃនិយ័តករគណនេយ្យនិងសវនកម្ម អមដោយថ្នាក់ដឹកនាំនិងមន្ត្រីជំនាញនៃនិយ័តករ គណនេយ្យនិងសវនកម្ម ព្រមទាំងមានការអញ្ជើញចូលរួមពី **លោក សាយ សុខខេង** អគ្គនាយក ក្រុមហ៊ុនឌីអេស្វស៊ី។ ក្នុងឱកាសដ៏វិសេសវិសាលនេះ **ឯកឧត្តមអគ្គនាយក** បានថ្លែងអំណរគុណដល់ ថ្នាក់ដឹកនាំ មន្ត្រីស្ថាប័នទាំងពីរដែលបានសហការរៀបចំវគ្គបណ្តុះបណ្តាលដ៏មានសារៈសំខាន់នេះ ជាពិសេស លោក លោកស្រី សិក្ខាកាម ដែលបាន ចូលរួមក្នុងវគ្គបណ្តុះបណ្តាលនេះផងដែរ។ **ឯកឧត្តមអគ្គនាយក** ក៏បានបន្ថែមនូវអត្ថប្រយោជន៍មួយចំនួននៃវគ្គបណ្តុះបណ្តាលរួមមាន៖ ១.ផ្តល់ឱ្យម្ចាស់សហគ្រាសនូវស្ថានភាពនិងលទ្ធផលហិរញ្ញវត្ថុ ដែលជួយដល់ការគ្រប់គ្រង សកម្មភាពអាជីវកម្ម ទាំងមូលដើម្បីសម្រេចបានទៅតាមគោលដៅដែលបានរំពឹងទុក ២. ភាពទុកចិត្តនៃរបាយការណ៍ ហិរញ្ញវត្ថុពីវិនិយោគិននិងទទួលបានឥណទានដោយងាយស្រួល, ៣.ទាក់ទាញការវិនិយោគពីវិនិយោគិន និងដៃគូអន្តរជាតិ និង ៤.ដើម្បីឱ្យមានគណនេយ្យភាព និងតម្លាភាព ជូនស្ថាប័នពាក់ព័ន្ធ ក៏ដូចការប្រមូលពន្ធសម្រាប់ប្រយោជន៍ថវិកាជាតិ។

## កិច្ចប្រជុំគណៈកម្មាធិការសម្របសម្រួលគណនេយ្យករជំនាញអាស៊ានលើកទី២៦ (26th ACPACC)



១៦.កាលពីថ្ងៃពុធ១៥កើត ដល់ព្រហស្បតិ៍១រោច ខែមាឃ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី១២-១៣ ខែកុម្ភៈ គ.ស.២០២៥ **លោកស្រី នាន បូនី** អគ្គនាយករង នៃនិយ័តករគណនេយ្យនិងសវនកម្ម តំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ម៉ូ ថារិន អគ្គនាយក** នៃនិយ័តករគណនេយ្យនិងសវនកម្ម និងជាប្រធានគណៈកម្មាធិការសម្របសម្រួលគណនេយ្យករជំនាញអាស៊ាន បានដឹកនាំអង្គប្រជុំគណៈកម្មាធិការ

សម្របសម្រួលគណនេយ្យករជំនាញអាស៊ានលើកទី២៦ (26th ACPACC) និងតំណាងគណៈកម្មាធិការសម្រួសបម្រួលគណនេយ្យករជំនាញអាស៊ានដើម្បីរាយការណ៍លទ្ធផលកិច្ចប្រជុំជូនកិច្ចប្រជុំក្រុមការងារតាមវិស័យ (BSSWG) នៅទីក្រុងប៉េណាង ប្រទេសម៉ាឡេស៊ី ដែលមានការអញ្ជើញចូលរួមតំណាងប្រទេសកម្ពុជាដោយ លោក ណុប សម្បត្តិ អនុប្រធាននាយកដ្ឋាន និងមន្ត្រីនៃនិយ័តករគណនេយ្យនិងសវនកម្ម រួមជាមួយនឹងតំណាងប្រទេសជាសមាជិកអាស៊ានទាំង៩។

## កិច្ចប្រជុំលើកទី៥ របស់គណៈកម្មាធិការគ្រប់គ្រងកម្មវិធីសិក្សាគណនេយ្យករជំនាញកម្ពុជា




១៧.កាលពីថ្ងៃចន្ទ ៥រោច ខែមាឃ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី១៧ ខែកុម្ភៈ គ.ស.២០២៥ នៅបន្ទប់ប្រជុំធំ អគារ "ក" ជាន់ទី១ នៃនិយ័តករគណនេយ្យនិងសវនកម្ម **ឯកឧត្តម ងី តាយី រដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការគ្រប់គ្រងកម្មវិធីសិក្សាគណនេយ្យករជំនាញកម្ពុជា** បានដឹកនាំកិច្ចប្រជុំលើកទី៥ របស់គណៈកម្មាធិការគ្រប់គ្រងកម្មវិធីសិក្សាគណនេយ្យករជំនាញកម្ពុជា ដោយមានការអញ្ជើញចូលរួមពី **ឯកឧត្តម ម៉ី ថារិន អគ្គនាយក** នៃនិយ័តករគណនេយ្យនិងសវនកម្ម និងជាអនុប្រធានប្រចាំការនៃគណៈកម្មាធិការគ្រប់គ្រងកម្មវិធីសិក្សាគណនេយ្យករជំនាញកម្ពុជា ព្រមទាំងមានការចូលរួមពីសមាជិកទីប្រឹក្សា និងលេខាធិការដ្ឋានរបស់គណៈកម្មាធិការគ្រប់គ្រងកម្មវិធីសិក្សាគណនេយ្យករជំនាញកម្ពុជា ដើម្បីពិនិត្យនិងសម្រេចលទ្ធផលប្រឡងឆមាសទី២ ក្នុងឆ្នាំ២០២៤ និងពិនិត្យសេចក្តីព្រាងយុទ្ធសាស្ត្រអភិវឌ្ឍន៍កម្មវិធីសិក្សាគណនេយ្យករជំនាញកម្ពុជា ២០២៥-២០៣០ របស់កម្មវិធីសិក្សាគណនេយ្យករជំនាញកម្ពុជា។

## កិច្ចប្រជុំក្រុមការងារជំរុញការអនុវត្តយុទ្ធសាស្ត្រនានារបស់ និយ័តករគណនេយ្យនិងសវនកម្ម




១៨.កាលពីថ្ងៃអង្គារ ៦រោច ខែមាឃ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី១៨ ខែកុម្ភៈ គ.ស.២០២៥ នៅបន្ទប់ប្រជុំធំ អគារ "ក" ជាន់ទី១ នៃនិយ័តករគណនេយ្យនិងសវនកម្ម **ឯកឧត្តម ម៉ី ថារិន អគ្គនាយក** នៃនិយ័តករគណនេយ្យនិងសវនកម្ម បានដឹកនាំកិច្ចប្រជុំក្រុម

ការងារជំរុញការអនុវត្តយុទ្ធសាស្ត្រនានារបស់ និយ័តករគណនេយ្យនិងសវនកម្ម ដោយមានការចូលរួមពីអនុប្រធាន និងសមាជិកនៃក្រុមការងារដើម្បីតាមដាន ត្រួតពិនិត្យ និងវាយតម្លៃទៅលើវឌ្ឍនភាពនៃការអនុវត្តយុទ្ធសាស្ត្រនានា ដែលបានដាក់ចេញដោយ ន.គ.ស.។

## កិច្ចប្រជុំពិភាក្សាជាមួយជំនាញការរបស់សហភាពអឺរ៉ុប



១៩.កាលពីថ្ងៃអង្គារ ៦រោច ខែមាឃ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី១៨ ខែកុម្ភៈ គ.ស.២០២៥ **លោកស្រី នាន បូនី** អគ្គនាយករង តំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ម៉ូ ថារិន អគ្គនាយក** នៃនិយ័តករគណនេយ្យនិងសវនកម្ម អមដោយអនុប្រធាននាយកដ្ឋានបច្ចេកទេស និងមន្ត្រីជំនាញនៃនាយកដ្ឋានបច្ចេកទេស បានចូលរួមកិច្ចប្រជុំពិភាក្សាជាមួយជំនាញការរបស់សហភាពអឺរ៉ុប និងតំណាងអគ្គនាយកដ្ឋានរតនាគារជាតិអំពី "ផែនការសម្រាប់គាំទ្រការអនុវត្តសកម្មភាពកែទម្រង់គន្លឹះ ក្រោមក្របខណ្ឌកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៤" នៅសាលប្រជុំជាន់ទី៣ នៃអគ្គនាយកដ្ឋានរតនាគារជាតិ។

## កិច្ចប្រជុំគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ




២០.កាលពីថ្ងៃពុធ ៧រោច ខែមាឃ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី១៩ ខែកុម្ភៈ គ.ស.២០២៥ **ឯកឧត្តម ម៉ូ ថារិន អគ្គនាយក** នៃនិយ័តករគណនេយ្យនិងសវនកម្ម អមដោយថ្នាក់ដឹកនាំនាយកដ្ឋាន និងការិយាល័យជំនាញ បានចូលរួមកិច្ចប្រជុំគណៈកម្មាធិការ ដឹកនាំ

ការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដើម្បីពិនិត្យ និងពិភាក្សាលើរបាយការណ៍តាមដាន និងវាយតម្លៃប្រចាំឆ្នាំ២០២៤ នៃការអនុវត្តកម្មវិធី កែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី៤ តាមរយៈប្រព័ន្ធអនឡាញ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងការងារ ហិរញ្ញវត្ថុសាធារណៈ។**

## កិច្ចប្រជុំពិភាក្សាស្តីពីការចូលរួមអភិវឌ្ឍវិស័យគណនេយ្យនៅកម្ពុជា




២១.កាលពីថ្ងៃពុធ ៧រោច ខែមាឃ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី១៩ ខែកុម្ភៈ គ.ស.២០២៥ នៅបន្ទប់ប្រជុំធំ អគារ"ក" ជាន់ទី១ នៃនិយ័តរគណនេយ្យនិងសវនកម្ម បានរៀបចំកិច្ចប្រជុំពិភាក្សាស្តីពីការចូលរួមអភិវឌ្ឍវិស័យគណនេយ្យនៅកម្ពុជា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ម៉ី ថារិន អគ្គនាយក** នៃនិយ័តកររគណនេយ្យនិងសវនកម្ម អមដោយថ្នាក់ដឹកនាំ និងនិងមន្ត្រីបច្ចេកទេស នៃ **ន.គ.ស.** ព្រមទាំងមានការអញ្ជើញចូលរួមពី លោក សោភាន់ ចៃត្រា ប្រធាន ក្លឹបគណនេយ្យកម្ពុជា។

## កិច្ចប្រជុំពិនិត្យពិភាក្សាលើការរៀបចំនីតិវិធីបង់ចំណូលមិនមែនសារពើពន្ធតាមមូលដ្ឋានបង្គរ




២២.កាលពីថ្ងៃពុធ ៧រោច ខែមាឃ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី១៩ ខែកុម្ភៈ គ.ស.២០២៥ ដោយមានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម ម៉ី ថារិន អគ្គនាយក** នៃនិយ័តកររគណនេយ្យនិងសវនកម្ម លោកស្រី ពេជ្រ ម៉ានីឡា អនុប្រធាននាយកដ្ឋាន អមដោយមន្ត្រីបច្ចេកទេសបានចូលរួមកិច្ចប្រជុំពិនិត្យពិភាក្សាលើការរៀបចំនីតិវិធីបង់ចំណូលមិនមែនសារពើពន្ធតាមមូលដ្ឋានបង្គរ  ក្រោមការដឹកនាំរបស់ លោក ជា វណ្ណារ័ត្ន ប្រធាននាយកដ្ឋានចំណូលថវិកា នៃអគ្គនាយកដ្ឋានរតនាគារជាតិ តាមប្រព័ន្ធអនឡាញ។

## ពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា
## "ស្តីពីកិច្ចសហប្រតិបត្តិការក្នុងការសម្រុះសម្រួលផ្សះផ្សាវិវាទ"



២៣.កាលពីថ្ងៃអង្គារ ៦រោច ខែមាឃ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី១៨ ខែកុម្ភៈ គ.ស.២០២៥ ដោយទទួលបានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម ម៉ូ ថារិន អគ្គនាយក** នៃនិយ័តករគណនេយ្យនិងសវនកម្ម លោក លី កុសល អនុប្រធានទទួលបន្ទុករួមនាយកដ្ឋានកិច្ចការគតិយុត្តនិងអនុលោមភាពនិងមន្ត្រីជំនាញ បានចូលរួមក្នុងពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា "ស្តីពីកិច្ចសហប្រតិបត្តិការក្នុងការសម្រុះសម្រួលផ្សះផ្សាវិវាទ" រវាងនិយ័តករមូលបត្រកម្ពុជា និងនិយ័តករសន្តិសុខសង្គមជាមួយអាជ្ញាធរជាតិដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ។ ក្នុងពិធីនេះក៏មានការអញ្ជើញចូលរួមពីតំណាងក្រសួង-ស្ថាប័នពាក់ព័ន្ធ មេធាវី និងវិស័យឯកជនផងដែរ។

## វគ្គបណ្តុះបណ្តាលស្តីពី "ការត្រួតពិនិត្យរបាយការណ៍ហិរញ្ញវត្ថុ ( Financial Statements Review Training )"




២៤.កាលពីថ្ងៃចន្ទ ៥រោច ខែមាឃ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២៥ ដោយទទួលបានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម ម៉ូ ថារិន អគ្គនាយក** នៃនិយ័តករគណនេយ្យនិងសវនកម្ម មន្ត្រីជំនាញនៃនិយ័តករគណនេយ្យនិងសវនកម្ម បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពី "ការត្រួតពិនិត្យរបាយការណ៍ហិរញ្ញវត្ថុ ( Financial Statements Review Training )" នៅស្ថាប័នបណ្តុះបណ្តាល TYMBA ដែលមានទីស្នាក់ការនៅ ទីក្រុងកូឡាឡាំពួរ ប្រទេសម៉ាឡេស៊ី។

## កិច្ចប្រជុំក្រុមការងារសម្របសម្រួលកិច្ចការសម្រាប់ការទទួលការវាយតម្លៃសមាជិកភាពកម្ពុជា ស្តីពីវេទិកាសកលស្តីពីតម្លាភាព និងការផ្លាស់ប្តូរព័ត៌មានដើម្បីគោលបំណងពន្ធ




© រក្សាសិទ្ធិដោយ និយ័តករគណនេយ្យនិងសវនកម្ម

២៥.កាលពីថ្ងៃព្រហស្បតិ៍ ៨រោច ខែមាឃ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ត្រូវនឹងថ្ងៃទី២០ ខែកុម្ភៈ គ.ស.២០២៥ ដោយទទួលបានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម ម៉ី ថារិន អគ្គនាយក** នៃនិយ័តករគណនេយ្យនិងសវនកម្ម លោក លី កុសល និង លោកស្រី ពេជ្រ ម៉ានីឡា អនុប្រធាននាយកដ្ឋាន នៃ **ន.គ.ស.** អមដោយមន្ត្រីជំនាញ បានចូលរួមកិច្ចប្រជុំក្រុមការងារសម្របសម្រួលកិច្ចការសម្រាប់ការទទួលការវាយតម្លៃសមាជិកភាពកម្ពុជា ស្តីពីវេទិកាសកលស្តីពីតម្លាភាព និងការផ្លាស់ប្តូរព័ត៌មានដើម្បីគោលបំណងពន្ធ តាមប្រព័ន្ធអនឡាញ។

## សិក្ខាសាលាផ្សព្វផ្សាយស្តីពី "កាតព្វកិច្ចគណនេយ្យនិងសវនកម្ម និងបទប្បញ្ញត្តិពាក់ព័ន្ធ" សម្រាប់សហគ្រាស និងអង្គភាពមិនស្វែងរកប្រាក់ចំណេញ



២៦.កាលពីថ្ងៃអង្គារ ១៣រោច ខែមាឃ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី២៤ ខែកុម្ភៈ គ.ស.២០២៥ និយ័តករគណនេយ្យនិងសវនកម្មនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពី "កាតព្វកិច្ចគណនេយ្យនិងសវនកម្ម និងបទប្បញ្ញត្តិពាក់ព័ន្ធ" សម្រាប់សហគ្រាស និងអង្គភាពមិនស្វែងរកប្រាក់ចំណេញ។ សិក្ខាសាលានេះប្រព្រឹត្តទៅក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ម៉ី ថារិន អគ្គនាយក** នៃនិយ័តករគណនេយ្យនិងសវនកម្ម អមដោយថ្នាក់ដឹកនាំនិងមន្ត្រីនៃនិយ័តករគណនេយ្យនិងសវនកម្ម ព្រមទាំងវត្តមានរបស់ តំណាងសហគ្រាស និងអង្គភាពមិនស្វែងរកប្រាក់ចំណេញ ចំនួន១៨០នាក់។

## កិច្ចប្រជុំពិភាក្សាស្តីពីការអនុវត្តស្តង់ដាគណនេយ្យសម្រាប់គ្រឹះស្ថានសាធារណៈរដ្ឋបាលនៅកម្ពុជា



២៧.កាលពីថ្ងៃចន្ទ ១២រោច ខែមាឃ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី២៤ ខែកុម្ភៈ គ.ស.២០២៥ **ឯកឧត្តម ម៉ី ថារិន អគ្គនាយក** នៃនិយ័តករគណនេយ្យនិងសវនកម្ម អមដោយមន្ត្រីជំនាញនៃនាយកដ្ឋានបច្ចេកទេស បានចូលរួមកិច្ចប្រជុំពិភាក្សាស្តីពីការអនុវត្តស្តង់ដាគណនេយ្យសម្រាប់គ្រឹះស្ថានសាធារណៈរដ្ឋបាលនៅកម្ពុជា ជាមួយនិយ័តករសន្តិសុខសង្គម ក្រោមអធិបតីភាព **ឯកឧត្តមបណ្ឌិត ចន ណារិទ្ធ អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអគ្គនាយកនៃនិយ័តករសន្តិសុខសង្គម** ដោយមានការចូលរួមពីតំណាងអគ្គនាយកដ្ឋានរតនាគារជាតិ និងអគ្គនាយកដ្ឋានថវិកា នៅបន្ទប់ប្រជុំធំ អគារ "គ" នៃទីស្តីការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## កិច្ចប្រជុំលើកទីមួយរបស់គណៈកម្មការបច្ចេកទេសគាំទ្រការអនុវត្តស្តង់ដាគណនេយ្យស្តង់ដាសវនកម្មនិងការអះអាង និងក្រមសីលធម៌វិជ្ជាជីវៈសម្រាប់វិស័យឯកជន



២៨.កាលពីថ្ងៃពុធ ១៤រោច ខែមាឃ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី២៦ ខែកុម្ភៈ គ.ស.២០២៥ នៅបន្ទប់ប្រជុំធំនិយ័តករគណនេយ្យ និងសវនកម្ម ជាន់ទី១ អគារ "ក" នៃទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ **ឯកឧត្តម ប៊ូ ថារិន អគ្គនាយក** នៃនិយ័តករគណនេយ្យនិងសវនកម្ម បានដឹកនាំកិច្ចប្រជុំលើកទីមួយ របស់គណៈកម្មការបច្ចេកទេសគាំទ្រការអនុវត្តស្តង់ដាគណនេយ្យស្តង់ដាសវនកម្ម និងការអះអាង និងក្រមសីលធម៌វិជ្ជាជីវៈ សម្រាប់វិស័យឯកជន ដោយមានការចូលរួមពី លោក លោកស្រី ដែលជាសមាជិក គ.ប.អ.ស.។ របៀបវារៈនៃកិច្ចប្រជុំរួមមាន៖១-ប្រកាសសមាសភាពគណៈកម្មការនិង២-ពិភាក្សាអំពីក្របខណ្ឌកាត់បន្ថយរបាយការណ៍ហិរញ្ញវត្ថុនិងមាតិកាគណនី។

## ចូលរួមសន្និបាតបូកសរុបលទ្ធផលការងារ ប្រចាំឆ្នាំ២០២៤ របស់សមាគមអគ្គិសនីជនបទ



២៩.កាលពីថ្ងៃអង្គារ ១៣រោច ខែមាឃ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី២៥ ខែកុម្ភៈ គ.ស.២០២៥ នៅជឺព្រៃមៀសេនជ័រសែនសុខ ដោយមានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម ប៊ូ ថារិន អគ្គនាយក** នៃនិយ័តករគណនេយ្យនិងសវនកម្ម លោក សឿន បូតេ អនុប្រធាននាយកដ្ឋានកិច្ចការគតិយុត្ត និងអនុលោមភាព បានដឹកនាំមន្ត្រីជំនាញ ចូលរួមសន្និបាតបូកសរុបលទ្ធផលការងារ ប្រចាំឆ្នាំ២០២៤ របស់សមាគមអគ្គិសនីជនបទ ក្រោមអធិបតីភាព **ឯកឧត្តម យឹម វិសិដ្ឋ** ប្រធានអាជ្ញាធរអគ្គិសនីកម្ពុជា ព្រមទាំងមានការចូលរួមពីតំណាងក្រសួងពាណិជ្ជកម្ម អគ្គនាយកដ្ឋានពន្ធដារ អគ្គិសនីកម្ពុជា សភាពាណិជ្ជកម្មកម្ពុជា និងភាគីពាក់ព័ន្ធ។

## សិក្ខាសាលាផ្សព្វផ្សាយច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម និងបទប្បញ្ញត្តិពាក់ព័ន្ធ ជូនសាស្ត្រាចារ្យ និងនិស្សិត នៃសាកលវិទ្យាល័យ អាស៊ី អឺរ៉ុប



៣០.កាលពីថ្ងៃព្រហស្បតិ៍ ១កើត ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស.៥៦៨ ត្រូវនឹងថ្ងៃទី២៧ ខែកុម្ភៈ គ.ស.២០២៥ និយ័តករគណនេយ្យ និងសវនកម្ម នៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ សហការជាមួយ សាកលវិទ្យាល័យ អាស៊ី អឺរ៉ុប បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយ

©រក្សាសិទ្ធិដោយ និយ័តករគណនេយ្យនិងសវនកម្ម

ច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម និងបទប្បញ្ញត្តិពាក់ព័ន្ធ ជូនសាស្ត្រាចារ្យ និងនិស្សិត នៃសាកលវិទ្យាល័យ អាស៊ី អឺរ៉ុប ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ម៉ូ ថារិន អគ្គនាយក** នៃនិយ័តករគណនេយ្យនិងសវនកម្ម។ សិក្ខាសាលានេះមានការអញ្ជើញចូលរួមពី **ឯកឧត្តម សាស្ត្រាចារ្យបណ្ឌិត សួស សោភា** សាកលវិទ្យាធិការរង នៃសាកលវិទ្យាល័យ អាស៊ី អឺរ៉ុប តំណាងដ៏ខ្ពង់ខ្ពស់ **អ្នកឧកញ៉ា លី យុនថៃ** ប្រធានក្រុមប្រឹក្សាភិបាល នៃសាកលវិទ្យាល័យ អាស៊ី អឺរ៉ុប ព្រមទាំង**លោកស្រី សារុធ ដាលី** នាយកប្រតិបត្តិ នៃវិទ្យាស្ថានគណនេយ្យករជំនាញនិងសវនករកម្ពុជា ថ្នាក់ដឹកនាំ មន្ត្រី នៃនិយ័តករគណនេយ្យនិងសវនកម្ម លោកគ្រូ អ្នកគ្រូ និងសិស្ស និស្សិត ចំនួន២៧០នាក់។

## សិក្ខាសាលាផ្សព្វផ្សាយច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ



៣១.កាលពីថ្ងៃព្រហស្បតិ៍ ១កើត ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី២៧ ខែកុម្ភៈ គ.ស.២០២៥ ដោយមានការអនុញ្ញាតដ៏ខ្ពង់ខ្ពង់ពី **ឯកឧត្តម ម៉ូ ថារិន អគ្គនាយក** នៃនិយ័តករគណនេយ្យនិងសវនកម្ម លោក លី កុសល អនុប្រធានទទួលបន្ទុករួមនៃនាយកដ្ឋានកិច្ចការគតិយុត្តនិងអនុលោមភាព បានដឹកនាំមន្ត្រីជំនាញ ចូលរួមសិក្ខាសាលាផ្សព្វផ្សាយច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ក្រោមអធិបតីភាព លោក ង៉ោ ដាឡែន អគ្គលេខាធិការរង នៃ អគ្គលេខាធិការដ្ឋាន អ.ស.ហ.។ សិក្ខាសាលានេះក៏មានអញ្ជើញចូលរួមពីតំណាងអង្គភាពក្រោមឱវាទ អ.ស.ហ. តំណាងមន្ទីរពាក់ព័ន្ធ សហគ្រាស និងសិស្ស និស្សិតចំនួន២០០ នាក់។

## សិក្ខាសាលាផ្សព្វផ្សាយ ច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម និងបទប្បញ្ញត្តិពាក់ព័ន្ធ ជូនសាស្ត្រាចារ្យ និងនិស្សិត នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា



៣២.កាលពីថ្ងៃសុក្រ ២កើត ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស.៥៦៨ ត្រូវនឹងថ្ងៃទី២៨ ខែកុម្ភៈ គ.ស.២០២៥ និយ័តករគណនេយ្យនិងសវនកម្ម នៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ សហការជាមួយ សាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម និងបទប្បញ្ញត្តិពាក់ព័ន្ធ ជូនសាស្ត្រាចារ្យ និងនិស្សិត នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា ក្រោម


© រក្សាសិទ្ធិដោយ និយ័តករគណនេយ្យនិងសវនកម្ម
Facebook Website Telegram

អធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ម៉ូ ថារិន អគ្គនាយក** នៃនិយ័តករគណនេយ្យនិងសវនកម្ម អមដោយថ្នាក់ដឹកនាំ និងមន្ត្រី នៃយ័តករគណនេយ្យនិងសវនកម្ម។ សិក្ខាសាលានេះមានការអញ្ជើញចូលរួមពី **បណ្ឌិត សំ ជិនហូ** ព្រឹទ្ធបុរសរងមហាវិទ្យាល័យសេដ្ឋសាស្ត្រ និងពាណិជ្ជសាស្ត្រ តំណាងដ៏ខ្ពង់ខ្ពស់ **លោកតាបណ្ឌិត កុល ផេង** ជាស្ថាបនិក និងជាសាកលវិទ្យាធិការនៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា ព្រមទាំង**លោកស្រី សារុជ ដាលី** នាយកប្រតិបត្តិ នៃវិទ្យាស្ថានគណនេយ្យករជំនាញនិងសវនករកម្ពុជា ថ្នាក់ដឹកនាំ មន្ត្រីនៃនិយ័តករគណនេយ្យនិងសវនកម្ម លោកគ្រូ អ្នកគ្រូ និងសិស្ស និស្សិត ចំនួន១៦០នាក់។ សិក្ខាសាលានេះត្រូវបានរៀបចំឡើងក្នុងគោលបំណងផ្សព្វផ្សាយនិងបញ្ជ្រាបការការយល់ដឹងអំពីច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងច្បាប់គណនេយ្យនិងសវនកម្ម ស្តង់ដាបច្ចេកទេសនៅកម្ពុជា ជូនដល់សាស្ត្រាចារ្យ និងនិស្សិតដែលកំពុងសិក្សាជំនាញពាក់ព័ន្ធ។

រៀបចំដោយ ÷ **លោក ឡាយ វិចិត្រ**

សម្របសម្រួលអត្ថបទ ÷ **កញ្ញា សុខ ណារី**

© រក្សាសិទ្ធិដោយ និយ័តករគណនេយ្យនិងសវនកម្ម